ឯកសារទិន្នន័យគម្រោង (PDS) ដែលបកប្រែនេះ គឺផ្អែកទៅតាមសំណៅភាសាអង់គ្លេសចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៤។

ADB

# ឯកសារទិន្នន័យគម្រោង

ឯកសារទិន្នន័យគម្រោង (PDS) រួមមាន ព័ត៌មានសង្ខេបអំពីគម្រោង ឬកម្មវិធី ៖ ដោយសារតែ PDS គឺជាការងារដែលត្រូវធ្វើជាបន្តបន្ទាប់ ព័ត៌មានមួយចំនួនអាចមិនទាន់ត្រូវបានដាក់បញ្ចូលនៅក្នុងសំណៅដំបូងនេះនៅឡើយ ប៉ុន្តែនឹងត្រូវបន្ថែមនៅពេលដែលមាន។ ព័ត៌មានអំពីគម្រោងដែលត្រូវបានស្នើឡើង គឺត្រឹមតែជាព័ត៌មានបណ្តោះអាសន្នតែប៉ុណ្ណោះ។

| | |
|---|---|
| **កាលបរិច្ឆេទបង្កើត PDS** | – |
| **PDS ត្រូវបានធ្វើបច្ចុប្បន្នកម្មត្រឹមកាលបរិច្ឆេទ** | ១១ កញ្ញា ២០១៤ |

| | |
|---|---|
| **ឈ្មោះគម្រោង** | គម្រោងគ្រប់គ្រងធនធានទឹក និងធារាសាស្ត្រនៅតំបន់ខ្ពង់រាប |
| **ប្រទេស** | ប្រទេសកម្ពុជា |
| **លេខគម្រោង/កម្មវិធី** | ៤៤៣២៨-០១៣ |
| **ស្ថានភាព** | ត្រូវបានស្នើឡើង |
| **ទីតាំងភូមិសាស្ត្រ** | – |

នៅក្នុងការរៀបចំកម្មវិធី ឬយុទ្ធសាស្ត្រប្រចាំប្រទេសណាក៏ដោយ ការផ្តល់ហិរញ្ញប្បទានដល់គម្រោងអ្វីក៏ដោយ ឬការលើកឡើង ឬយោងលើដែនដី ឬតំបន់ភូមិសាស្ត្រណាមួយ នៅក្នុងឯកសារនេះ ធនាគារអភិវឌ្ឍន៍អាស៊ីមិនមានបំណងធ្វើការវិនិច្ឆ័យអំពីស្ថានភាពគតិយុត្ត ឬស្ថានភាពដទៃទៀតរបស់ដែនដី ឬតំបន់នោះឡើយ។

| | |
|---|---|
| **ចំណាត់ថ្នាក់វិស័យ និង/ឬអនុវិស័យ** | – |
| **ចំណាត់ថ្នាក់ប្រធានបទ** | – |
| **ប្រភេទនៃការបញ្ជ្រាបយេនឌ័រ** | – |

## ការផ្តល់ហិរញ្ញប្បទាន

| ប្រភេទ/ទម្រង់នៃការផ្តល់ជំនួយ | លេខអនុម័ត | ប្រភពមូលនិធិ | ចំនួនដែលត្រូវបានអនុម័ត (គិតជាពាន់) |
|---|---|---|---|
| កម្ចី | – | មូលនិធិអភិវឌ្ឍន៍អាស៊ី | ៣៥.000 |
| – | – | សមភាគី | ៥.000 |
| សរុប | | | ៤0.000 ដុល្លារ |

## ប្រភេទនៃការការពារផ្នែកបរិស្ថាន និងសង្គម

សម្រាប់ព័ត៌មានបន្ថែមអំពីប្រភេទនៃការការពារផ្នែកបរិស្ថាន និងសង្គម សូមមើលៈ
http://www.adb.org/site/safeguards/safeguard-categories

| | |
|---|---|
| បរិស្ថាន | B |
| ការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត | B |
| ក្រុមជនជាតិដើមភាគតិច | C |

## សង្ខេបបញ្ហាបរិស្ថាន និងសង្គម

**ទិដ្ឋភាពបរិស្ថាន**

–

**ការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត**

–

**ក្រុមជនជាតិដើមភាគតិច**

–

## ■ ការប្រាស្រ័យទាក់ទង ការចូលរួម និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ

### ក្នុងកំឡុងពេលរៀបចំគម្រោង

សហគមន៍កសិករអ្នកប្រើប្រាស់ទឹក (FWUCs) នឹងចូលរួមនៅក្នុងដំណើរការនៃការរៀបចំគម្រោង។ វានឹងមានការពិគ្រោះយោបល់ជាមួយនឹង FWUCs នៅក្នុងកំឡុងពេលអនុវត្តគម្រោងជំនួយបច្ចេកទេសសម្រាប់រៀបចំគម្រោង តាមរយៈការពិភាក្សាក្រុមគោលដៅ កិច្ចប្រជុំពិគ្រោះយោបល់ជាមួយសហគមន៍ និងការចុះបំពេញការងារជាប្រចាំថ្ងៃនៅមូលដ្ឋាន។ ការរៀបចំបញ្ជីលំអិតអំពីអង្គការសង្គមស៊ីវិលផ្សេងទៀត នឹងត្រូវធ្វើឡើង ហើយនឹងមានការពិគ្រោះយោបល់ជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការងារពាក់ព័ន្ធនឹងវិស័យទឹក និងធារាសាស្ត្រ។

### ក្នុងកំឡុងពេលអនុវត្តគម្រោង

កិច្ចព្រមព្រៀង សម្រាប់អនុគម្រោង នឹងត្រូវចុះហត្ថលេខាជាមួយនឹង FWUCs ដែលចូលរួមនៅក្នុងការអនុវត្តអនុគម្រោង និងទទួលយកភារកិច្ចប្រើប្រាស់ និងថែទាំប្រព័ន្ធធារាសាស្ត្រកម្រិតទី ៣។

## ■ សេចក្តីពិពណ៌នា

–

## ■ សនិទានភាព និងទំនាក់ទំនងរបស់គម្រោងជាមួយនឹងយុទ្ធសាស្ត្រប្រចាំប្រទេស/តំបន់

គម្រោងនេះនឹងបំពេញបន្ថែមលើផលរយៈពេលវែង និងផលរយៈពេលមធ្យម របស់កម្មវិធីអភិវឌ្ឍន៍ពាណិជ្ជភាវូបនីយ-កម្មស្រូវ-អង្ករ ដែលធន់ទៅនឹងអាកាសធាតុ (ហៅកាត់ជាភាសាអង់គ្លេសថា Rice-SDP) ដែលទទួលបានការអនុម័ត នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៣។ ការស្តារឡើងវិញ/ការធ្វើឱ្យប្រព័ន្ធធារាសាស្ត្រធន់ទៅនឹងអាកាសធាតុ ការសាងសង់កន្លែងសម្រាប់សំអាត សំងួត បែងចែកតាមកម្រិតថ្នាក់ និងរក្សាទុកគ្រាប់ពូជ និងការសាងសង់កន្លែងសំងួត និងរក្សាទុកស្រូវ ត្រូវបានធ្វើឡើងនៅតាមបណ្តាខេត្តទាំងនេះ ក្រោមគម្រោង Rice-SDP។ តំបន់ខ្ពង់រាប មានសក្តានុពលបង្កើនផលិតភាពដី និងទឹក តាមរយៈការកែលំអប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងធនធានទឹក ដែលនឹងរួមចំណែកសម្រេចលទ្ធផលរបស់កម្មវិធី។ គម្រោងនេះ ក៏នឹងជួយកែលំអ ការគ្រប់គ្រងទឹក នៅតំបន់វាលទំនាបផងដែរ ក៏ដូចជាបន្ថែមគុណតម្លៃដល់គម្រោងនានា ដែលកំពុងអនុវត្តនៅជុំវិញបឹងទន្លេសាប ក្រោមហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ តំបន់គម្រោងនេះ រួមមាន ប្រព័ន្ធ

ធារាសាស្ត្រ ដែលត្រូវបានជ្រើសរើស នៅក្នុង ខេត្តទាំង ៣។ គម្រោងនេះ នឹងដាក់បញ្ចូលរបកគំហើញ និងអនុសាសន៍ដែលមាននៅក្នុងយុទ្ធសាស្ត្ររបស់វិស័យនេះ ដូចជា (i) ការ បង្កើនផលិតភាពកសិកម្ម (ii) ការលើកកម្ពស់ពិពិធកម្ម (iii) ការគាំទ្រដល់ការធ្វើពាណិជ្ជភាវូបនីយកម្ម និងការភ្ជាប់ទំនាក់ទំនង (សង្វាក់ផ្គត់ផ្គង់ និងការភ្ជាប់ទំនាក់ទំនងទីផ្សារ) (iv) ការគាំទ្រដល់ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព (v) និរន្តរភាពបរិស្ថាន និងការប្រែប្រួលអាកាសធាតុ (vi) ការអភិវឌ្ឍយេនឌ័រ និង (vii) ការដោះស្រាយបញ្ហាប្រឈមផ្នែកស្ថាប័ន។ គម្រោងនេះ ត្រូវផ្តោតការយកចិត្តទុកដាក់ជាក់លាក់លើឧបសគ្គ ដែលធ្វើឱ្យរាំងស្ទះដល់ផលិតភាពកសិកម្ម ដូចជា (i) ប្រសិទ្ធភាពនៃប្រព័ន្ធធារាសាស្ត្រ និងផលិតភាពទឹកនៅមានកម្រិតទាប (ii) ភាពមានទឹកមានការប្រែប្រួលតាមរដូវកាល (iii) ការប្រើប្រាស់ និងការថែទាំពុំមានគ្រប់គ្រាន់ និង (iv) ការគ្រប់គ្រងធនធានទឹកនៅខ្សោយ។ គម្រោងនេះ នឹងទទួលបានប្រយោជន៍ពីកំណែទម្រង់គោលនយោបាយ និងគំនិតផ្តួចផ្តើមពង្រឹងស្ថាប័ននៃកម្មវិធីអភិវឌ្ឍន៍វិស័យគ្រប់គ្រងធនធានទឹក (WRMSDP) ដែលទទួលបានហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី។ ដំណើរការកំណែទម្រង់គ្រប់ជ្រុងជ្រោយមួយ កំពុងអនុវត្តក្រោម WRMSDP នេះ ដើម្បីបង្កើតនូវបរិយាកាសច្បាប់ដែលមានលក្ខណៈអំណោយផល និងរៀបចំស្ថាប័ន ដែលមានរចនាសម្ព័ន្ធត្រឹមត្រូវ គួបផ្សំជាមួយនឹងកម្មវិធីកសាងសមត្ថភាពសម្រាប់ស្ថាប័នរដ្ឋាភិបាល សំដៅធានាឱ្យមានការគ្រប់គ្រងធនធានទឹកប្រកបដោយនិរន្តរភាព។ គម្រោងនេះនឹងប្រើប្រាស់សមិទ្ធផលដែលសម្រេចបានរបស់កម្មវិធី WRMSDP និងបន្តជម្រុញការអនុវត្តកំណែទម្រង់គោលនយោបាយ និងវិធានការពង្រឹងស្ថាប័ន នៅក្នុងតំបន់គម្រោង។ គម្រោងនេះនឹង (i) ធ្វើការស្តារឡើងវិញ/ធ្វើទំនើបកម្មប្រព័ន្ធធារាសាស្ត្រ ដែលធន់នឹងអាកាសធាតុ និងកែលំអដំណើរការ និងការគ្រប់គ្រងប្រព័ន្ធទាំងនេះ (ii) បង្កើនផលិតភាពដី និងទឹក តាមរយៈការគ្រប់គ្រងទីជម្រាល និងការកែលំអដីធ្លី និង (iii) កែលំអការគ្រប់គ្រងធនធានទឹក តាមរយៈការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ និងធនធានទឹកតាមបែបចូលរួម។ កសិកម្ម គឺជាប្រភពមុខរបរចិញ្ចឹមជីវិតចម្បងមួយ និងជាប្រភពចំណូលសម្រាប់ប្រជាពលរដ្ឋ ក៏ដូចជាសម្រាប់ប្រទេសជាតិទាំងមូល នៅក្នុងប្រទេសកម្ពុជា។ វិស័យកសិកម្មចូលរួមចំណែកជិត ៣៦% នៃ GDP របស់ជាតិ។ វិស័យនេះគឺជាគន្លឹះសម្រាប់សន្តិសុខស្បៀងក្នុងប្រទេស និងការបង្កើនចំណូលពីការនាំចេញ។ វិស័យកសិកម្មផ្តល់នូវការងារប្រមាណជា ៥១% នៃចំនួនការងារសរុប បើធៀបជាមួយនឹងតួលេខជាមធ្យម ៣៧% នៅក្នុងអាស៊ីទាំងមូល។ ជាមួយនឹងកម្លាំងពលកម្មមួយភាគធំកំពុងបំពេញការងារក្នុងវិស័យកសិកម្ម ការបង្កើនផលិតភាពអាចចូលរួមចំណែកនាំឱ្យមានកំណើនសម្រាប់ទាំងអស់គ្នា តាមរយៈការបង្កើនប្រាក់ចំណូលរបស់គ្រួសារ ដែលនាំឱ្យមានការកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ។ ខេត្តទាំង ៣ នេះមានស្រុកចំនួន ៣២ ដែលក្នុងនោះស្រុកចំនួន ២១ នៅឆ្ងាយពីបឹងទន្លេសាប។ ប្រជាពលរដ្ឋ ដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រគឺ ២៧% នៅក្នុងខេត្តបាត់ដំបង និង ២០% នៅក្នុងខេត្តព្រៃវែង។ ទឹក គឺជាធនធានដ៏សំខាន់ សម្រាប់ផលិតកម្មកសិកម្ម ការបង្កើនផលិតភាព និងកំណើនសេដ្ឋកិច្ច។ របាយទឹកភ្លៀង និងបរិមាណទឹកទន្លេ មានការប្រែប្រួលខ្លាំង ទៅតាមរដូវកាល នៅក្នុងប្រទេសកម្ពុជា ដែលបង្កឱ្យមានផលប៉ះពាល់ជាអវិជ្ជមានមកលើផលិតកម្មកសិកម្មប្រកបដោយនិរន្តរភាព។ ការប្រែប្រួលអាកាសធាតុទំនងជាធ្វើឱ្យស្ថានភាពនេះកាន់តែធ្ងន់ធ្ងរឡើងៗ។ ការមានទឹកទាន់ពេលវេលា និងការគ្រប់គ្រងទឹកប្រកបដោយប្រសិទ្ធភាព មានសារៈសំខាន់

យ៉ាងខ្លាំងចំពោះផលិតភាពកសិកម្ម និងការធ្វើពិពិធកម្មកសិកម្ម។ ការខូចខាតហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ កំពុងបង្កជាផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ផលិតភាពកសិកម្ម។ ការវិនិយោគលើការស្តារ និងការកែលំអហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ អាចមិនទទួលបានប្រយោជន៍ទៅតាមការចង់បាន ប្រសិនបើដីមិនអំណោយផលសម្រាប់ការបង្កបង្កើនផលដែលមានស្រាប់ ឬដែលកើតមាន ទៅតាមការចង់បាន។ ដូច្នេះ ការបែងចែកតំបន់ប្រើប្រាស់ដីធ្លី ដែលកំពុងធ្វើឡើងក្រោមកម្មវិធី Rice-SDP នឹងបង្កើតបានជាមូលដ្ឋានសម្រាប់កំណត់ពិលក្ខណៈ និងវិសាលភាពនៃការស្តារ/ការធ្វើទំនើបកម្ម ដែលចាំបាច់ ដើម្បីឱ្យប្រព័ន្ធធារាសាស្ត្រអាចបំពេញទៅតាមតម្រូវការទឹកសម្រាប់ដំណាំ។ ការបង្កើនផលិតភាពកសិកម្ម ការធ្វើពិពិធកម្ម និងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ និងធនធានទឹក គឺជាការងារសំខាន់ៗ ដែលត្រូវបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រជាតិរបស់រដ្ឋាភិបាល ដូចជា យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ដំណាក់កាលទី ៣ ជាដើម។ យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (CPS: ២០១៤-២០១៨) ក៏ផ្តោតការយកចិត្តទុកដាក់លើកំណើនសេដ្ឋកិច្ចសម្រាប់ទាំងអស់គ្នាផងដែរ តាមរយៈសកម្មភាពពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត កសិកម្ម និងធារាសាស្ត្រ ។ល។ គម្រោងនេះគាំទ្រដល់យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ីផង និងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលផង ហើយត្រូវបានតម្រឹមឱ្យស្របទៅតាមធាតុចេញទី ៣ នៃផែនទីបង្ហាញផ្លូវសម្រាប់វិស័យនេះ និងក្របខ័ណ្ឌលទ្ធផលនៃយុទ្ធសាស្ត្រតាមវិស័យរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ គម្រោងនេះនឹងប្រើប្រាស់ទម្រង់ការតាមវិស័យ ដូច្នេះ វានឹងមានការវាយតម្លៃលើអនុគម្រោងនៅក្នុងដំណាក់កាលនៃការអនុវត្តគម្រោងនេះ។

## ផលប៉ះពាល់នៃការអភិវឌ្ឍ

ចំណូលរបស់កសិដ្ឋាន នៅក្នុងតំបន់គម្រោង មានការកើនឡើង។

## លទ្ធផលរយៈពេលមធ្យមរបស់គម្រោង

| សេចក្តីពិពណ៌នាអំពីលទ្ធផលរយៈពេលមធ្យម | វឌ្ឍនភាពឆ្ពោះទៅសម្រេចលទ្ធផលរយៈពេលមធ្យម |
|---|---|
| ផលិតភាពទឹក និងកសិកម្មត្រូវបានលើកកម្ពស់ | – |

## លទ្ធផល និងវឌ្ឍនភាពនៃការអភិវឌ្ឍ

| សេចក្តីពិពណ៌នាអំពីលទ្ធផលរបស់គម្រោង | ស្ថានភាពនៃការអនុវត្ត (លទ្ធផល សកម្មភាព និងបញ្ហា) |
|---|---|
| ១. បង្កើនប្រសិទ្ធភាព និងភាពធន់ទៅនឹងអាកាសធាតុនៃប្រព័ន្ធធារាសាស្ត្រ។ ២. លើកកម្ពស់ការគ្រប់គ្រងធនធានទឹក។ ៣. កែលំអការគ្រប់គ្រងគម្រោង។ | – |
| **ស្ថានភាពនៃគោលដៅអភិវឌ្ឍ** | **ការផ្លាស់ប្តូរសំខាន់ៗ** |
| – | – |

## ឱកាសធុរកិច្ច

| | |
|---|---|
| **កាលបរិច្ឆេទនៃការចុះបញ្ជីដំបូង** | – |

**សេវាពិគ្រោះយោបល់**

–

**លទ្ធកម្ម**

–

**សេចក្តីជូនដំណឹងអំពីលទ្ធកម្ម និងការពិគ្រោះយោបល់**

http://www.adb.org/projects/44328-013/business-opportunities

## កាលវិភាគ

| | |
|---|---|
| **ការឯកភាពលើទស្សនទាន** | ១៤ សីហា ២០១៤ |
| **ការស្វែងរកការពិត** | ០១ មិថុនា ២០១៥ ដល់ ១៥ មិថុនា ២០១៥ |
| **កិច្ចប្រជុំពិនិត្យឡើងវិញរបស់ថ្នាក់គ្រប់គ្រង** | ៣០ សីហា ២០១៥ |
| **ការអនុម័ត** | – |
| **បេសកកម្មពិនិត្យឡើងវិញចុងក្រោយ** | – |

## ■ ចំណុចដៅ

| លេខអនុម័ត | ការអនុម័ត | ចុះហត្ថលេខា | ចូលជាធរមាន | បិទ | | |
|---|---|---|---|---|---|---|
| | | | | សំណៅដើម | ត្រូវបានកែសម្រួល | ជាក់ស្តែង |
| – | – | – | – | – | – | – |

## ■ ការប្រើប្រាស់

| កាលបរិច្ឆេទ | ការអនុម័តលេខ | ADB (ពាន់ US$) | ផ្សេងៗទៀត (ពាន់ US$) | ភាគរយសុទ្ធ |
|---|---|---|---|---|
| ចំនួនសរុបក្នុងការផ្តល់កិច្ចសន្យា | | | | |
| – | – | – | – | – |
| ការបើកប្រាក់សរុប | | | | |
| – | – | – | – | – |

## ■ ស្ថានភាពនៃកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងត្រូវបានបែងចែកតាមប្រភេទដូចតទៅ - របាយការណ៍ហិរញ្ញវត្ថុរបស់គម្រោងដែលត្រូវបានធ្វើសវនកម្មរួច ការគាំពារបិស្ថាន សង្គម កិច្ចការសង្គម កិច្ចការវិស័យហិរញ្ញវត្ថុ សេដ្ឋកិច្ច និងកិច្ចការផ្សេងៗទៀត។ ការអនុលោមទៅតាមកិច្ចព្រមព្រៀង ត្រូវបានដាក់ពិន្ទុទៅតាមប្រភេទ ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យដូចតទៅ: (១) ពេញចិត្តៈ អនុលោមទាំងអស់ទៅតាមគ្រប់កិច្ចព្រមព្រៀង ដោយមានករណីលើកលែងច្រើនបំផុតត្រឹម ១ ដែលអនុញ្ញាតឱ្យមាន (២) ពេញចិត្តដោយអន្លឹះ ច្រើនបំផុត មានកិច្ចព្រមព្រៀងចំនួន ២ ដែលមិនត្រូវបានអនុលោមតាម (៣) មិនពេញចិត្តៈ មានកិច្ចព្រមព្រៀងចាប់ពី ៣ ឡើងទៅដែលមិនត្រូវបានអនុលោមតាម។ យោងតាមគោលនយោបាយស្តីពីការប្រាស្រ័យទាក់ទងសាធារណៈឆ្នាំ ២០១១ ការវាយតម្លៃនៃភាពអនុលោមរបស់កិច្ចព្រមព្រៀង សម្រាប់របាយការណ៍ហិរញ្ញវត្ថុរបស់គម្រោង អនុវត្តតែចំពោះគម្រោង ដែលលិខិតអញ្ជើញឱ្យចរចាក្រោយថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១២ តែប៉ុណ្ណោះ។

| ការអនុម័តលេខ | ប្រភេទ | | | | | | |
|---|---|---|---|---|---|---|---|
| | វិស័យ | សង្គម | ហិរញ្ញវត្ថុ | សេដ្ឋកិច្ច | ផ្សេងៗ | ការគាំពារបរិស្ថានសង្គម | របាយការណ៍ហិរញ្ញវត្ថុរបស់គម្រោង |
| កម្ចី - | – | – | – | – | – | – | – |

## ផ្នែកទំនាក់ទំនង និងព័ត៌មានបច្ចុប្បន្នភាព

| | |
|---|---|
| **មន្ត្រី ADB ដែលទទួលខុសត្រូវ** | Raza Mahmood Farrukh (rfarrukh@adb.org) |
| **នាយកដ្ឋាន ADB ដែលទទួលខុសត្រូវ** | នាយកដ្ឋានអាស៊ីអាគ្នេយ៍ |
| **ការិយាល័យ ADB ដែលទទួលខុសត្រូវ** | ផ្នែកបរិស្ថាន ធនធានធម្មជាតិ និងកសិកម្មរបស់ SERD |
| **ទីភ្នាក់ងារប្រតិបត្តិ** | – |

## ឯកសារសម្រាប់មើលព័ត៌មានផ្សេងៗទៀត

| | |
|---|---|
| **គេហទំព័ររបស់គម្រោង** | http://www.adb.org/projects/44328-013/main |
| **បញ្ជីឯកសារគម្រោង** | http://www.adb.org/projects/44328-013/documents |